AMRO
ASEAN +3 MACROECONOMIC RESEARCH OFFICE

10 Shenton Way
#15-08, MAS Building
Singapore 079117
T: +65 6323 9844
F: +65 6223 8187
www.amro-asia.org

# ទស្សនវិស័យសេដ្ឋកិច្ចតំបន់អាស៊ានបូកបី ឆ្នាំ ២០១៩
# ASEAN+3 Regional Economic Outlook (AREO) 2019
# សេចក្តីសង្ខេប

## ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងបញ្ហាប្រឈម

តំបន់អាស៊ានបូកបីត្រូវបានរំពឹងថា នឹងរក្សាបាននូវភាពធន់ បើទោះជាប្រឈមនូវហានិភ័យសកល ដែលអាចមានផលប៉ះពាល់ខ្លាំងជាងមុនដល់ប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់ (emerging economies) ក៏ដោយ។ កំណើនសេដ្ឋកិច្ចសកលត្រូវបានរំពឹងថា អាចនឹងថមថយក្នុងឆ្នាំ ២០១៩ - ២០២០ ដោយសារភាពមានកម្រិតនៃវដ្តសេដ្ឋកិច្ចរបស់ប្រទេសមហាអំណាចសេដ្ឋកិច្ចទាំងបី (G3), ការថយចុះនៃចំណាយមូលធន និងការចំណាយលើបច្ចេកវិទ្យា, ព្រមទាំងភាពមិនប្រាកដប្រជានៃសង្គ្រាមពាណិជ្ជកម្មពិភពលោក។ បណ្តាប្រទេសដែលមានសេដ្ឋកិច្ចបើកចំហ និងពឹងផ្អែកខ្លាំងលើពាណិជ្ជកម្ម អាចនឹងទទួលរងនូវផលប៉ះពាល់ពីការថមថយនៃតម្រូវការខាងក្រៅ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ តំបន់អាស៊ានបូកបីបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីរក្សាមូលដ្ឋានគ្រឹះរបស់ខ្លួន។ ប្រទេសសមាជិកភាគច្រើនស្ថិតក្នុងវដ្តសេដ្ឋកិច្ចកម្រិតកណ្តាល (mid-phase of the business cycle) ដែលកំណើនសេដ្ឋកិច្ចស្ថិតក្នុងអត្រាប្រហាក់ប្រហែលនឹងកំណើននិន្នាការរយៈពេលវែង (long-term trend) ហើយគម្លាតទិន្នផលសេដ្ឋកិច្ច (output gap) កៀ្បរនឹងសូន្យ ខណៈដែលអតិផរណាស្ថិតក្នុងកម្រិតគោលដៅគោលនយោបាយ (policy targets) ឬប្រហាក់ប្រហែលនឹងអត្រានិន្នាការរយៈពេលវែង។ បើទោះជាលំហគោលនយោបាយ (policy space) កាន់តែរួមតូចក្តី អ្នករៀបចំគោលនយោបាយគួរបន្តប្រើប្រាស់នូវវិធីសាស្ត្រផ្សេងៗ និងបង្កើនទ្រនាប់ (buffers) ដើម្បីទប់ទល់នឹងហានិភ័យពីខាងក្រៅ ក៏ដូចជាដើម្បីគ្រប់គ្រងភាពមិនប្រាកដប្រជា ដែលកើតឡើងដោយសារភាពអន្តរអាស្រ័យនៃម៉ាក្រូសេដ្ឋកិច្ច (macroeconomic interdependence)។

អស្ថិរភាពក្នុងទីផ្សារហិរញ្ញវត្ថុបានកើតឡើងជាថ្មីម្តងទៀតចាប់តាំងពីឆមាសទី ២ ឆ្នាំ ២០១៨ ដែលភាគច្រើនបណ្តាលមកពីភាពមិនប្រាកដប្រជានៃពាណិជ្ជកម្មសកល។ ការចំណាយលើកម្ចីកាន់តែខ្ពស់ជាងមុន និងការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិកបានបង្កឱ្យមានភាពតានតឹងផ្នែកហិរញ្ញវត្ថុ (financial stress) ក្នុងប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់ ជាពិសេសប្រទេសដែលមានបញ្ហារចនាសម្ព័ន្ធ ដែលជំរុញឱ្យវិនិយោគិនមិនហ៊ានប្រឈមនឹងហានិភ័យ (risk aversion) ហើយលក់ភាគហ៊ុនចេញពីទីផ្សារដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់។ ការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុសកលមានផលប៉ះពាល់ជាខ្លាំងដល់តំបន់អាស៊ី ជាពិសេសប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន

ដែលការចំណាយលើកម្ចីបានកើនឡើងយ៉ាងគំហុក។ លំហូរចេញមូលធនពីតំបន់មានប្រមាណជា ៦ ប៊ីលានដុល្លារអាមេរិក ក្នុងអំឡុងខែកញ្ញា និងតុលា ដោយសារវិនិយោគិនបានលក់ចេញនូវផលបត្រវិនិយោគ (portfolios)។

ការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ប្រទេសធំៗមួយចំនួននាពេលថ្មីៗនេះគួរតែអាចកាត់បន្ថយនូវសម្ពាធនៃលំហូរចេញមូលធនពីតំបន់។ ឈានចូលដល់ឆ្នាំ ២០១៩ ការថមថយនៃសូចនាករសេដ្ឋកិច្ចសំខាន់ៗ និងការរំពឹងទុកថាសេដ្ឋកិច្ចសកលជារួម (រួមបញ្ចូលទាំងចិន) នឹងមានកំណើនយឺតជាងមុន បានធ្វើឱ្យទីផ្សារហិរញ្ញវត្ថុកាន់តែមានអស្ថិរភាព។ ប្រក្រតីយកម្មគោលនយោបាយរូបិយវត្ថុរបស់អាមេរិក និងសហគមន៍អឺរ៉ុបបានសបញ្ជាក់ឱ្យឃើញពីក្ដីបារម្ភទាក់ទងនឹងការថមថយនៃកំណើនសេដ្ឋកិច្ចសកល។ នាពេលខាងមុខនេះ ការបន្ធូរបន្ថយលក្ខខណ្ឌហិរញ្ញវត្ថុសកលនឹងអាចជួយទ្រទ្រង់កំណើន ប្រសិនបើគោលនយោបាយត្រូវបានអនុវត្តឱ្យចំគោលដៅ ដែលអាចជួយផ្ដល់សញ្ញាដ៏ត្រឹមត្រូវដល់ទីផ្សារហិរញ្ញវត្ថុ។

យោងតាមការវាយតម្លៃជាមូលដ្ឋាន (baseline) តំបន់អាស៊ានបូកបីនឹងមានកំណើនថមថយបន្តិចបន្តួចក្នុងឆ្នាំ ២០១៩-២០២០ បើប្រៀបធៀបទៅនឹងឆ្នាំ ២០១៨ ប៉ុន្តែជាមួយគ្នានេះផងដែរ តំបន់នេះនឹងជួបប្រទះនូវភាពមិនប្រាកដប្រជាកាន់តែច្រើនជាងមុន។ បើទោះជាទស្សនវិស័យសេដ្ឋកិច្ចមានភាពថមថយក៏ដោយ ក៏មូលដ្ឋានគ្រឹះសេដ្ឋកិច្ចជារួម (underlying prospects) នៅបន្តមានភាពរឹងមាំផងដែរ។ កំណើនមូលដ្ឋានតំបន់ត្រូវបានព្យាករថា នឹងស្ថិតក្នុងអត្រា ៥,១ ភាគរយ ក្នុងឆ្នាំ ២០១៩-២០២០ (៥,៣ ភាគរយ ក្នុងឆ្នាំ ២០១៨) ដោយគិតបញ្ចូលទាំងផលប៉ះពាល់ដែលបណ្ដាលមកពីវិធានការគាំពារពាណិជ្ជកម្មនាពេលកន្លងមក។ អតិផរណាត្រូវបានរំពឹងថានឹងមានស្ថិរភាពក្នុងអត្រាប្រមាណ ២ ភាគរយ បើធៀបទៅនឹងឆ្នាំ ២០១៨។ ការព្យាករកំណើនសេដ្ឋកិច្ចប្រទេសចិនត្រូវបានកែប្រែខ្ពស់ជាងមុនបន្តិច ពោលគឺក្នុងអត្រា ៦,៣ ភាគរយ (បើធៀបនឹង ៦,២ ភាគរយ ក្នុងរបាយការណ៍របស់ AMRO (២០១៩)) សម្រាប់ឆ្នាំ ២០១៩ និង ៦,២ ភាគរយ សម្រាប់ឆ្នាំ ២០២០។ កំណើនសេដ្ឋកិច្ចជប៉ុនត្រូវបានព្យាករថានឹងស្ថិតក្នុងអត្រា ០,៦ ភាគរយ ក្នុងឆ្នាំសារពើពន្ធ (fiscal year) ២០១៩ និងថមថយមកត្រឹម ០,៥ ភាគរយ ក្នុងឆ្នាំសារពើពន្ធ ២០២០។ តំបន់អាស៊ានទាំងមូលត្រូវបានព្យាករថា នឹងរក្សាបាននូវកំណើនក្នុងអត្រា ៥,១ ភាគរយ ក្នុងឆ្នាំ ២០១៩ និង ៥,២ ភាគរយក្នុងឆ្នាំ ២០២០។

តំបន់អាស៊ានបូកបីនឹងមិនអាចជៀសផុតពីការរងការប៉ះទង្គិចពីហានិភ័យមួយចំនួន ដែលបណ្ដាលមកពីការថមថយនៃពាណិជ្ជកម្មសកល។ ភាពមិនប្រាកដប្រជាជុំវិញបញ្ហាពាណិជ្ជកម្មនឹងនៅតែបន្តកើនឡើង ខណៈដែលហានិភ័យពីភាពតានតឹងកាន់តែខ្លាំងឡើងនៃសង្គ្រាមពាណិជ្ជកម្មពិភពលោកនៅតែជាបញ្ហាចម្បង ដែលទាមទារការយកចិត្តទុកដាក់ខ្ពស់ បើទោះជាមានវឌ្ឍនភាពខ្លះៗទាក់ទងនឹងការចរចាពាណិជ្ជកម្មរវាងចិន និងសហរដ្ឋអាមេរិកក៏ដោយ។ ហានិភ័យពីកិច្ចគាំពារពាណិជ្ជកម្មនេះអាចជះឥទ្ធិពលដល់តំបន់ តាមរយៈការនាំចេញ និងខ្សែចង្វាក់តម្លៃសកល (global value chains) ហើយទំហំនៃផលប៉ះពាល់នេះនឹងរីកកាន់តែធំ ដោយសារផលប៉ះពាល់ដោយប្រយោលផ្សេងៗទៀត (second-order effects) ដែលកើតឡើងនៅពេលដែលសេដ្ឋកិច្ចពិភពលោកមានកំណើនយឺតជាងមុន។ ប្រទេសក្នុងតំបន់ដែលនាំចេញច្រើនទៅប្រទេសចិនដោយផ្ទាល់ និងដោយប្រយោលតាមរយៈខ្សែចង្វាក់តម្លៃសកលសម្រាប់បំពេញតម្រូវការក្រៅតំបន់ នឹងទទួលរងនូវការប៉ះទង្គិចខ្លាំងជាងប្រទេសផ្សេងទៀត

ក្នុងរយៈពេលខ្លី។ ប្រទេសដែលមានសេដ្ឋកិច្ចបើកចំហខ្លាំង និងពឹងផ្អែកខ្លាំងលើពាណិជ្ជកម្ម ដូចជាហុងកុង, កូរ៉េ, ម៉ាឡេស៊ី, សិង្ហបុរី និងវៀតណាម គឺជាប្រទេសដែលងាយនឹងរងគ្រោះផងដែរ។

ចំពោះសេណារីយ៉ូអវិជ្ជមាន (adverse scenario) ភាពតានតឹងកាន់តែខ្លាំងឡើងនៃសង្គ្រាមពាណិជ្ជកម្មនឹងបណ្តាលឱ្យកំណើនសេដ្ឋកិច្ចមូលដ្ឋាន (baseline growth) ក្នុងតំបន់ថយចុះប្រមាណជា ០,៤ ពិន្ទុភាគរយ។ ក្នុងករណីនេះ សហរដ្ឋអាមេរិក និងចិនកំណត់យកពន្ធនាំចូល ២៥ ភាគរយលើទំនិញទាំងអស់រវាងប្រទេសទាំងពីរ។ ផលប៉ះពាល់រយៈពេលខ្លីដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសណាមួយក្នុងតំបន់នឹងមានទំហំកាន់តែធំ រហូតដល់ទៅ -១,០ ពិន្ទុភាគរយ។ ជាការពិតណាស់ សហរដ្ឋអាមេរិក និងចិននឹងអាចខាតបង់កាន់តែខ្លាំង ប្រសិនបើវិធានការមិនមែនពន្ធ (non-tariff measures) ត្រូវបានអនុវត្ត។ ចំពោះសហរដ្ឋអាមេរិក ផលប៉ះពាល់ដល់កំណើន (absolute impact) អាចមានទំហំតូច (-០,៣ ពិន្ទុភាគរយ) សម្រាប់ឆ្នាំ ២០១៩-២០២០ បើប្រៀបធៀបជាមួយចិន (-០,៦ ពិន្ទុភាគរយ)។ ក៏ប៉ុន្តែផលប៉ះពាល់ធៀបនឹងកំណើន (relative impact) មានទំហំធំជាងសម្រាប់សហរដ្ឋអាមេរិក ពោលគឺ ១៣ ភាគរយនៃកំណើនមធ្យមប្រចាំឆ្នាំ ២០១៩-២០២០ បើប្រៀបធៀបជាមួយចិន (ក្រោម ១០ ភាគរយ)។

ដោយហេតុថាហានិភ័យកំពុងតែកើនឡើងខ្លាំងជាងមុន ប្រទេសនានាក្នុងតំបន់គួរបន្តការយកចិត្តទុកដាក់ក្នុងការអនុវត្តគោលនយោបាយឱ្យកាន់តែសកម្មជាងមុន។ ប្រទេសសមាជិកមួយចំនួនបានអនុវត្តនូវវិធានការគោលនយោបាយបុរេសកម្ម (pre-emptive or frontloaded policy measures) ដែលអាចជួយបន្ធូរបន្ថយភាពតានតឹងក្នុងទីផ្សារហិរញ្ញវត្ថុ។ ប្រទេសសមាជិកខ្លះទៀតបានរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់ខ្លួន ដើម្បីរក្សានូវស្ថិរភាពថ្លៃទាំងក្នុងប្រទេស និងក្រៅប្រទេស ក៏ដូចជាដើម្បីកាត់បន្ថយហានិភ័យដែលអាចប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុ ស្របពេលដែលអត្រាការប្រាក់បន្តមានកម្រិតទាបក្នុងរយៈពេលយូរ។ វិធានការផ្សេងទៀត ដែលត្រូវបានអនុវត្តដើម្បីកាត់បន្ថយសម្ពាធលើគណនីចរន្ត (current account) រួមមាន ការពន្យារពេលលើគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលទាមទារនូវការនាំចូលច្រើនសន្ធឹកសន្ធាប់ (import-intensive infrastructure projects)។ ដោយឡែកចំពោះគោលនយោបាយសារពើពន្ធ ការអនុវត្តហិរញ្ញវត្ថុសាធារណៈបានល្អ បានជួយជំរុញឱ្យគោលនយោបាយសារពើពន្ធបញ្ច្រាសវដ្តធុរកិច្ច (countercyclical) ដើរតួនាទីយ៉ាងសំខាន់ បើទោះជានៅមានកម្រិតក៏ដោយ។ ប្រទេសសមាជិកក្នុងតំបន់បានអនុវត្តគោលនយោបាយសារពើពន្ធវិត្ថារកម្ម (expansionary policies) ឬ ប្រទេសណាមួយដែលអនុវត្តវិធានសារពើពន្ធ (fiscal rules) បានធ្វើអាទិភាពលើចំណាយសារជាថ្មី ស្របពេលដែលលំហសារពើពន្ធ (fiscal space) ក្នុងតំបន់បានរួមតូច។ បន្ទាប់ពីមានកំណើនខ្ពស់ជាងនិន្នាការដែលទ្រទ្រង់ដោយលក្ខខណ្ឌហិរញ្ញវត្ថុធូររលុងអស់មួយរយៈកន្លងមក ប្រទេសសមាជិកក្នុងតំបន់មួយចំនួនកំពុងស្ថិតក្នុងដំណាក់កាលយឺតនៃវដ្តឥណទាន (slowing phase of the credit cycle) ហើយប្រទេសមួយចំនួនបានបន្ធូរបន្ថយវិធានការម៉ាក្រូប្រុងប្រយ័ត្ន (macroprudential measures) ដើម្បីទ្រទ្រង់ដល់ការខ្ចី។

សម្រាប់រយៈពេលមធ្យម និងវែងខាងមុខ ប្រទេសនីមួយៗក្នុងតំបន់ចាំបាច់ត្រូវបំពេញកិច្ចការជាច្រើន ដើម្បីទ្រទ្រង់ដល់ទស្សនវិស័យកំណើនសេដ្ឋកិច្ច ក៏ដូចជាពង្រឹងភាពធន់របស់តំបន់។ កិច្ចការអាទិភាពក្នុងដំណាក់កាលបន្ទាប់ទៀតដែលតំបន់គួរបន្តកិច្ចខិតខំប្រឹងប្រែង គឺការអនុវត្តគោលនយោបាយអាទិភាព ដែលរួមមានការកសាង

សមត្ថភាព និងការតភ្ជាប់ ព្រមទាំងការពង្រឹងការអភិវឌ្ឍទីផ្សារមូលធនក្នុងស្រុកឱ្យបានកាន់តែទូលំទូលាយ។ តំបន់នេះបានរីកចម្រើនក្នុងអំឡុង ២ ទសវត្សរ៍កន្លងមកនេះ ដោយសារការអនុវត្តយុទ្ធសាស្ត្រ "ការផលិតដើម្បីនាំចេញ" ដែលជាសសរស្តម្ភនៃប្រទេសជាច្រើនក្នុងតំបន់។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការផ្លាស់ប្តូរពីការផលិតទៅសេវាកម្ម (transformation to services) គឺជារឿងមួយដែលមិនអាចជៀសផុត ហើយបញ្ហាដែលទាក់ទងនឹងការវិនិយោគលើវិស័យសំខាន់ៗ គួរចាំបាច់ត្រូវដោះស្រាយ ដើម្បីបង្កើត និងរក្សាកំណើនសេដ្ឋកិច្ចក្នុងតំបន់។

## ប្រធានបទស្នូលៈ ការកសាងការតភ្ជាប់ និងសមត្ថភាពសម្រាប់សេដ្ឋកិច្ចថ្មី

ការកសាងការតភ្ជាប់ និងសមត្ថភាព នឹងក្លាយជាការងារជាអាទិភាពរបស់តំបន់អាស៊ានបូកបី ខណៈដែលតំបន់នេះកំពុងព្យាយាមប្រែក្លាយខ្លួនទៅជា "សេដ្ឋកិច្ចថ្មី (new economy)" និងចាប់ផ្តើមឈានជើងលើវិថីកំណើនក្នុងដំណាក់កាលបន្ទាប់។ តំបន់នេះបានរីកចម្រើនក្នុងអំឡុង ២ ទសវត្សរ៍កន្លងមកនេះ ដោយសារការអនុវត្តយុទ្ធសាស្ត្រ "ការផលិតដើម្បីនាំចេញ" ដែលជាសសរស្តម្ភនៃប្រទេសជាច្រើនក្នុងតំបន់។ ខណៈដែលបច្ចេកវិទ្យាមានការវិវត្តកាន់តែខ្លាំងឡើង ហើយវិសមភាពនៃការប្រើប្រាស់បច្ចេកវិទ្យានៅតែបន្ត ការផ្លាស់ប្តូរទៅសេវាកម្មគឺជារឿងមួយដែលមិនអាចជៀសផុត ដែលទាមទារឱ្យមានការគិតគូរឡើងវិញទៅលើនិយមន័យនៃ "សមត្ថភាព (capacity)" និង "ការតភ្ជាប់ (connectivity)"។ ការវិនិយោគមិនគ្រប់គ្រាន់ (underinvestment) ជាបញ្ហាចម្បងមួយ ដែលនឹងជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ច ប្រសិនបើបញ្ហានេះមិនត្រូវបានដោះស្រាយឱ្យបានត្រឹមត្រូវ។ ប្រធានបទស្នូលសម្រាប់ឆ្នាំ ២០១៩ នេះ ត្រូវបានចងក្រងឡើងបន្តពីប្រធានបទស្នូលក្នុងឆ្នាំ ២០១៧ ដែលផ្តោតសំខាន់លើការពង្រឹងសេដ្ឋកិច្ច និងតុល្យភាពក្នុងតំបន់បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុអាស៊ី (Asian Financial Crisis) និងប្រធានបទស្នូលក្នុងឆ្នាំ ២០១៨ ដែលផ្តោតសំខាន់លើការពង្រឹងភាពធន់ និងកំណើន។

មានកត្តាជំរុញ (drivers) ចំនួន ៣ ដែលនឹងជះឥទ្ធិពលដល់ការកសាងសមត្ថភាព និងការតភ្ជាប់ក្នុងតំបន់សម្រាប់រយៈពេលខ្លី និងមធ្យមខាងមុខ។ ទីមួយ បច្ចេកវិទ្យា ឬ បដិវត្តន៍ឧស្សាហកម្មទី ៤ (technological or Fourth Industrial Revolution) ដែលជំរុញឱ្យមានស្វ័យប្រវត្តិកម្ម, បដិឧស្សាហនីយកម្ម (deindustrialization) និងការងើបឡើងនៃវិស័យសេវាកម្ម។ ទីពីរ កំណើននៃប្រជាជនពេញវ័យ (maturing population) និងការរីកសាយនៃប្រជាជនថ្នាក់កណ្តាល (middle class) នឹងជួយជំរុញដល់ការកសាងសមត្ថភាពផលិតកម្មប្រកបដោយចំណេះដឹង និងចំណេះធ្វើ ព្រមទាំងបង្កើនតម្រូវការទាំងទំនិញ និងសេវាក្នុងតំបន់ ដែលរួមមានកន្លែងរស់នៅដែលមានភាពប្រសើរឡើង ក៏ដូចជាសេវាថ្មីៗ និងតម្រូវការក្នុងការពង្រឹងការតភ្ជាប់។ ទីបី កិច្ចគាំពារពាណិជ្ជកម្មពីប្រទេសលោកខាងលិច ព្រមទាំងការកើនឡើងនៃតម្រូវការក្នុងតំបន់ នឹងជួយជំរុញសមាហរណកម្មតំបន់ឱ្យកាន់តែស៊ីជម្រៅថែមទៀត។

ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់ កំពុងជួបប្រទះនូវបញ្ហាប្រឈមយ៉ាងលំបាកជាច្រើនក្នុងការវិនិយោគរយៈពេលវែង លើវិស័យមួយចំនួនដែលប្រទេសទាំងនេះមិនមានលទ្ធភាពហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីវិនិយោគដោយខ្លួនឯង។ ការវិនិយោគនេះរួមមាន ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ, ធនធានមនុស្ស និងវត្ថុអរូបិយផ្សេងទៀតដែលជួយបង្កើនផលិតភាពជាតិ (national productivity)។ កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងតំបន់អាស៊ានបូកបីនឹងបង្កើតឱ្យមានតម្រូវការហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ក៏ដូចជា

បង្កឱ្យមានកង្វះការវិនិយោគកាន់តែធំជាងមុន។ បញ្ហាបម្រែបម្រួលអាកាសធាតុក៏បានរួមចំណែកធ្វើឱ្យប្រទេសក្នុងតំបន់ ដែលមានហេដ្ឋារចនាសម្ព័ន្ធទន់ខ្សោយ ប្រឈមនូវហានិភ័យដែលធ្វើឱ្យសេដ្ឋកិច្ចមានកំណើនទាបជាងមុន។

គម្លាតចំនួនបី ដែលជះឥទ្ធិពលដល់ការកសាងសមត្ថភាព និងការតភ្ជាប់ រួមមាន គម្លាតថវិកា (funding gap), គម្លាតរូបិយប័ណ្ណបរទេស (foreign exchange gap) និងគម្លាតកត្តាជំរុញពាក់ព័ន្ធ (factors gap)។ គម្លាតថវិកាសំដៅលើគម្លាតរវាងការវិនិយោគក្នុងស្រុក (រួមទាំងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ) និងការសន្សំក្នុងស្រុក។ គម្លាតរូបិយបណ្ណបរទេស គឺជាបញ្ហាផ្នែកហិរញ្ញប្បទាន ដែលកើតឡើងដោយសារការរក្សាទុកនូវទុនបម្រុងអន្តរជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់ ដើម្បីកាត់បន្ថយហានិភ័យពីលំហូរចេញមូលធនភ្លាមៗ។ គម្លាតកត្តាជំរុញពាក់ព័ន្ធសំដៅលើឧបសគ្គទាំងឡាយណាដែលមិនទាក់ទងនឹងហិរញ្ញវត្ថុ ពោលគឺសមត្ថភាពក្នុងគ្រប់គ្រង និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធនានា (នៅពេលដែលមានហិរញ្ញប្បទានគ្រប់គ្រាន់), កម្លាំងពលកម្មចាំបាច់, ព្រមទាំងជំនាញ ក៏ដូចជាការប្រើប្រាស់បច្ចេកវិទ្យា។

ដើម្បីកាត់បន្ថយគម្លាតទាំងនេះ តំបន់អាស៊ានបូកបីចាំបាច់ត្រូវទាញយកអត្ថប្រយោជន៍ពីការវិនិយោគក្នុងតំបន់ និងពឹងផ្អែកលើសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់ (regional financial safety net) ហើយជាមួយគ្នានេះដែរត្រូវខិតខំអភិវឌ្ឍជំនាញ, បច្ចេកវិទ្យា និងស្ថាប័ន។ តំបន់នេះនៅមានសក្ដានុពលក្នុងការវិនិយោគរយៈពេលវែង ដើម្បីពង្រឹងសមត្ថភាព និងការតភ្ជាប់ក្នុងតំបន់។ ប្រទេសអាស៊ានបូកបីដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់គួរបន្តអនុវត្តតាមឧត្តមានុវត្តន៍អន្តរជាតិរបស់ប្រទេសអភិវឌ្ឍន៍ ដែលនៅតែបន្តរក្សាតួនាទីយ៉ាងសំខាន់សម្រាប់តំបន់អាស៊ានបូកបីក្នុងការវិនិយោគលើការផ្ទេរបច្ចេកវិទ្យា ក៏ដូចជាការផ្លាស់ប្ដូរទៅ “សេដ្ឋកិច្ចថ្មី”។ ពហុភាគីនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (Chiang Mai Initiative Multilateralisation) ជាទំនិញសាធារណៈក្នុងតំបន់ (regional public good) មួយ ដែលផ្តល់នូវសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុសម្រាប់តំបន់អាស៊ានបូកបី។ ភាពចម្រុះនៃការអភិវឌ្ឍធនធានមនុស្ស, ជំនាញ និងបច្ចេកវិទ្យាក្នុងតំបន់អាស៊ានបូកបី ធ្វើឱ្យកិច្ចសហប្រតិបត្តិការក្នុងតំបន់នេះកាន់តែមានភាពជិតស្និទ្ធជាងមុន ដើម្បីបង្រួមគម្លាតនៅបណ្តាប្រទេសសមាជិកក្នុងតំបន់ និងធានាឱ្យបាននូវការប្រើប្រាស់ឱ្យអស់ពីលទ្ធភាពនូវធនធានកម្ររបស់តំបន់ ក៏ដូចជាការផ្តល់អត្ថប្រយោជន៍ទៅដល់តំបន់វិញផងដែរ។ ទន្ទឹមនឹងនេះ តំបន់អាស៊ានបូកបីគួរបង្កើតនូវគំនិតផ្តួចផ្តើមថ្មីៗបន្ថែមទៀត ដើម្បីពង្រឹងសមាហរណកម្ម និងការតភ្ជាប់ក្នុងតំបន់។

*បញ្ជាក់៖ សេចក្តីសង្ខេបជាភាសាខ្មែរនេះ ត្រូវបានប្រែសម្រួលចេញពីសេចក្តីសង្ខេបដើមជាភាសាអង់គ្លេស ដែលអាចស្កេនដើម្បីទាញយកបាន (scan to download) ។ សេចក្តីសង្ខេបនេះត្រូវបានប្រែសម្រួលយ៉ាងប្រុងប្រយ័ត្នបំផុត ដើម្បីធានាភាពត្រឹមត្រូវស្របតាមសំណេរដើម ប៉ុន្តែប្រសិនបើមានកំហុសឆ្គង ឬខ្វះចន្លោះត្រង់ចំណុចណាមួយនោះ សេចក្តីសង្ខេបជាភាសាអង់គ្លេសត្រូវបានកំណត់យកជាគោល។*